# សេចក្តីប្រកាស
# អង្គការសហប្រជាជាតិ
# ស្តីពីសិទ្ធិជនជាតិដើមភាគតិច

អង្គការសហប្រជាជាតិ

អង្គការសហប្រជាជាតិ
សិទ្ធិមនុស្ស
ការិយាល័យឧត្តមស្នងការ
កម្ពុជា


សហការឧបត្ថម្ភមូលនិធិដោយ
សហភាពអឺរ៉ុប


សហភាពអឺរ៉ុប

ការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្សប្រចាំកម្ពុជា

# សេចក្ដីប្រកាសរបស់អង្គការសហប្រជាជាតិ
# ស្ដីពី
# សិទ្ធិជនជាតិដើមភាគតិច

ឯកសារនេះត្រូវបានផលិតឡើងក្រោមការឧបត្ថម្ភផ្នែកហិរញ្ញវត្ថុពីសហភាពអឺរ៉ុប។ មតិយោបល់ទាំងឡាយមាននៅក្នុងឯកសារនេះមិនឆ្លុះបញ្ចាំងពីទស្សនៈរបស់សហភាពអឺរ៉ុបឡើយ។


អង្គការសហប្រជាជាតិ

អង្គការសហប្រជាជាតិ
សិទ្ធិមនុស្ស
ការិយាល័យឧត្ដមស្នងការ
កម្ពុជា

សហការឧបត្ថម្ភមូលនិធិដោយ
សហភាពអឺរ៉ុប

សហភាពអឺរ៉ុប



ការិយាល័យឧត្ដមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស
ការិយាល័យប្រចាំកម្ពុជា
*cambodia.ohchr.org*

បោះពុម្ពផ្សាយឡើងវិញ ខែតុលា ឆ្នាំ២០១៨

# អារម្ភកថា

មានជនជាតិដើមភាគតិច ប្រមាណជា៣៧០លាននាក់ រស់នៅក្នុងរដ្ឋសមាជិកនានារបស់អង្គការសហប្រជាជាតិ រួមទាំងកម្ពុជាផងដែរ។ ជនជាតិដើមភាគតិចប្រឈមមុខនឹងបញ្ហាជាច្រើន ជារឿយៗពាក់ព័ន្ធនឹងដីធ្លី វប្បធម៌ ភាសា និងប្រពៃណីផ្សេងៗ ដែលកំពុងតែទទួលការគៀបសង្កត់កាន់តែខ្លាំងឡើង ពីការអភិវឌ្ឍ និងសកលភាវូបនីយកម្ម។

នៅថ្ងៃទី១៣ ខែកញ្ញា ឆ្នាំ២០០៧ មហាសន្និបាតអង្គការសហប្រជាជាតិ បានអនុម័តសេចក្តីប្រកាសស្តីពី សិទ្ធិជនជាតិដើមភាគតិច។ សេចក្តីប្រកាសនេះ មិនបង្កើតសិទ្ធិថ្មីទេ ប៉ុន្តែមានគោលបំណង ដោះស្រាយស្ថានការណ៍ពិសេសផ្សេងៗរបស់ជនជាតិដើមភាគតិច និងការលំបាកជាក់ស្តែងដែលពួកគេប្រឈមមុខ ក្នុងការទាមទារសិទ្ធិរបស់ខ្លួនដែលមានស្រាប់ជាមនុស្សជាតិ។

សេចក្តីប្រកាសនេះ មានចែងអំពីសិទ្ធិទាំងឡាយដែលបានដំកល់ទុកក្នុងសេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស និងដែលបានធានាការពារក្នុងសន្ធិសញ្ញាសិទ្ធិមនុស្សអន្តរជាតិនានាដែលកម្ពុជាបានទទួលយក ។សន្ធិសញ្ញាទាំងនេះត្រូវបានដាក់បញ្ចូលទៅក្នុងរដ្ឋធម្មនុញ្ញកម្ពុជា ឆ្នាំ១៩៩៣ និងជាផ្នែកមួយនៃច្បាប់ជាតិ ។

សេចក្តីប្រកាសនេះ ចែងអំពីសិទ្ធិបុគ្គល និងសិទ្ធិសមូហភាពរបស់ជនជាតិដើមភាគតិច រួមទាំងសិទ្ធិរបស់ពួកគេលើដីធ្លី និងធនធានវប្បធម៌ អត្តសញ្ញាណ ភាសា ការងារ សុខភាពវប្បធម៌ ការសិក្សាអប់រំ និងបញ្ហាដទៃទៀត ។

សេចក្តីប្រកាសនេះ ទទួលស្គាល់សិទ្ធិជនជាតិដើមភាគតិចលើដីធ្លី ដែនដី និងធនធានផ្សេងៗដែលពួកគេមានកាន់កាប់ ឬប្រើប្រាស់ជាប្រពៃណី ហើយដែលរដ្ឋសមាជិកនានាត្រូវតែទទួលស្គាល់ និងការពារតាមផ្លូវច្បាប់ ។ ជនជាតិដើមភាគតិច មានទំនាក់ទំនងជាពិសេសខាងជំនឿ សាសនា ជា

មួយដីធ្លី ទឹកដីនិងធនធាននានាដែលជាស្នូលនៃអត្តសញ្ញាណវប្បធម៌ និងប្រពៃណីរបស់ខ្លួន ។

សេចក្តីប្រកាសនេះ បញ្ជាក់ពីសិទ្ធិជនជាតិដើមភាគតិចក្នុងការរក្សា និងពង្រឹងស្ថាប័នវប្បធម៌ និងប្រពៃណីរបស់ខ្លួន និងធ្វើការអភិវឌ្ឍ ស្របតាមសេចក្តីត្រូវការ និង បំណងប្រាថ្នារបស់ខ្លួនផ្ទាល់ ។

សេចក្តីប្រកាសនេះ ក៏ហាមឃាត់ផងដែរ ការរើសអើងប្រឆាំងជនជាតិដើមភាគតិច និងជំរុញឱ្យពួកគេចូលរួមយ៉ាងពេញលេញ និងប្រកបដោយប្រសិទ្ធភាពនៅគ្រប់បញ្ហាដែលពាក់ព័ន្ធនឹងខ្លួន ហើយសិទ្ធិរបស់ពួកគេ នៅតែមានជាពិសេស ហើយបន្តអនុវត្តតាមទស្សនៈរបស់ខ្លួនផ្ទាល់ក្នុងការអភិវឌ្ឍសេដ្ឋកិច្ច និងសង្គមកិច្ច ។

សេចក្តីប្រកាសនេះ មិនតម្រូវឱ្យផ្តល់សច្ចាប័ន នៅមុនពេលដែលសេចក្តីប្រកាសនេះចូលជាធរមានឡើយ ។ ទោះជាសេចក្តីប្រកាសនេះ មិនមែនជាអត្ថបទដែលភ្ជាប់កាតព្វកិច្ច

តាមផ្លូវច្បាប់ដូចជាតាមលក្ខណៈសន្និសញ្ញាអន្តរជាតិក៏ដោយ ក៏មានប្រទេសចំនួន១៨៣ រួមទាំងកម្ពុជាផង បានបោះឆ្នោតគាំទ្រអត្ថបទនេះ ដែលតំណាងឱ្យចំនួនភាគច្រើននៃរដ្ឋសមាជិកអង្គការសហប្រជាជាតិ។ ប្រទេសនានា ដែលបានបោះឆ្នោតគាំទ្រ តាមធម្មតាត្រូវបានគេរំពឹងថាគាំទ្រ និងអនុវត្តបទបញ្ញត្តិនៃសេចក្តីប្រកាសនេះចំពោះពលរដ្ឋនៃជនជនជាតិដើមភាគតិច នៅក្នុងប្រទេសរបស់ខ្លួន។

*យន្តការអង្គការសហប្រជាជាតិសំរាប់ជនជាតិដើមភាគតិច*

មានយន្តការអង្គការសហប្រជាជាតិមួយចំនួនត្រូវបានបង្កើតឡើងដើម្បីលើកស្ទួយសិទ្ធិជនជាតិដើមភាគតិចដូចជា៖

ក្រោមការឧបត្ថម្ភពីក្រុមប្រឹក្សាសិទ្ធិមនុស្សអង្គការសហប្រជាជាតិ អាណត្តិរបស់**អ្នករាយការណ៍ពិសេសរបស់អង្គការសហប្រជាជាតិ** ស្តីពីស្ថានការណ៍សិទ្ធិមនុស្ស និងសេរីភាពជាមូលដ្ឋានរបស់ជនជាតិដើមភាគតិច ត្រូវបានបង្កើតឡើងនៅក្នុងឆ្នាំ២០០១ ដើម្បីលើកស្ទួយសិទ្ធិជនជាតិដើមភាគតិច៣៤០លាននាក់ លើពិភពលោក ។

**វេទិកាអចិន្ត្រៃយ៍ស្តីពីបញ្ហាជនជាតិដើមភាគតិច** គឺជាស្ថាប័នដែលផ្តល់ការណែនាំដល់ក្រុមប្រឹក្សាសេដ្ឋកិច្ច និងសង្គមរបស់អង្គការសហប្រជាជាតិ ស្តីពីបញ្ហាជនជាតិដើមភាគតិច ទាក់ទងនឹងការអភិវឌ្ឍសេដ្ឋកិច្ច និងសង្គមកិច្ច វប្បធម៌ បរិស្ថាន អប់រំ សុខភាព និងសិទ្ធិមនុស្ស ។

**មូលនិធិសំរាប់ជនជាតិដើមភាគតិច** ត្រូវបានបង្កើតឡើងដោយមហាសន្និបាត ក្នុងឆ្នាំ១៩៨៥ ក្នុងគោលបំណងជួយដល់តំណាងរបស់សហគមន៍ និងអង្គការជនជាតិដើមភាគតិចនានា ដើម្បីចូលរួមក្នុងកិច្ចប្រជុំនៃស្ថាប័នអង្គការសហប្រជាជាតិពាក់ព័ន្ធនានា រួមទាំងវេទិការអចិន្ត្រៃយ៍ ។

*កម្មវិធីអាហារូបករណ៏សំរាប់ជនជាតិដើមភាគតិចរបស់ការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស*

ការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស (OHCHR) មានកម្មវិធីអាហារូបករណ៏សំរាប់ជនជាតិដើមភាគតិច ដែលមានបំណងផ្តល់ឱ្យតំណាងជនជាតិដើមភាគតិចនូវឱកាសសិក្សាអំពីប្រព័ន្ធ និងយន្តការអង្គការសហប្រជាជាតិដែលធ្វើការលើវិស័យសិទ្ធិមនុស្សជាទូទៅ និងលើបញ្ហាពាក់ព័ន្ធ នឹងជនជាតិដើម

ភាគតិចជាពិសេស។ សិក្ខាកាមចំណាយពេល ពីរ ទៅ បួនខែ នៅទីស្នាក់ការការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស ប្រចាំនៅទីក្រុងហ្សឺណែវ បន្ទាប់ពីសិក្សាអំពីការងាររបស់ការិយាល័យ ក្រុមប្រឹក្សាសិទ្ធិមនុស្ស ស្ថាប័នសន្ធិសញ្ញានានា និងយន្តការដទៃទៀត ដូច្នេះពួកគេអាចជួយដល់អង្គការ និងសហគមន៍របស់ខ្លួន ក្នុងការការពារ និងការលើកស្ទួយសិទ្ធិប្រជាជនរបស់ខ្លួន តាមរយៈយន្តការទាំងនេះ។

ដើម្បីទទួលបានព័ត៌មានបន្ថែមទៀតស្តីពីសេចក្តីប្រកាសកម្មវិធីអាហារូបករណ៍ និងវិធីផ្សេងៗទៀត ដែលអង្គការសហប្រជាជាតិ គាំទ្រដល់ជនជាតិដើមភាគតិច សូមទាក់ទងការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្សប្រចាំនៅកម្ពុជា។

ខែកញ្ញា ឆ្នាំ២០០៧

# សេចក្តីប្រកាសរបស់អង្គការសហប្រជាជាតិ ស្តីពីសិទ្ធិជនជាតិដើមភាគតិច

(អនុម័តដោយសេចក្តីសំរេចរបស់មហាសន្និបាត លេខ ៦១/២៩៥ ថ្ងៃទី ១៣ ខែកញ្ញា ឆ្នាំ ២០០៧)

## *មហាសន្និបាត*

*ដោយផ្អែក* លើគោលបំណង និងគោលការណ៍ផ្សេងៗនៃធម្មនុញ្ញសហប្រជាជាតិ និងលើសុច្ឆរិតភាពក្នុងការបំពេញកាតព្វកិច្ចដោយរដ្ឋទាំងឡាយស្របតាមធម្មនុញ្ញនេះ។

*ដោយអះអាងថា* ជនជាតិដើមភាគតិចមានសិទ្ធិស្មើគ្នាដូចប្រជាពលរដ្ឋដទៃទៀត ខណៈដែលមានការទទួលស្គាល់ថា មនុស្សទាំងអស់មានសិទ្ធិដើម្បីមានភាពផ្សេងពីគ្នា ជនជាតិដើមភាគតិច ចាត់ទុកខ្លួនឯងថាមានភាពផ្សេងពីគេ ហើយត្រូវតែគោរពដល់សិទ្ធិនៃភាពផ្សេងគ្នានេះ។

*ដោយអះអាងដែរថា* មនុស្សគ្រប់រូបរួមចំណែក បង្កើតនូវភាពចំរុះ និងភាពសម្បូរណ៏បែបនៃអារ្យធម៌ និងវប្បធម៌ ដែលបង្កើតបានជាមរតករួមរបស់មនុស្សជាតិ ។

*ដោយអះអាងបន្ថែមទៀតថា* លិទ្ធិ គោលនយោបាយ និងការអនុវត្តផ្សេងៗ ផ្អែកលើ ឬលើកកំពស់ឧត្តមភាពរបស់មនុស្ស ឬបុគ្គល ដោយឈរលើមូលដ្ឋានដើមកំណើត ជាតិសាសន៍ សាសនាឬភាពខុសគ្នាខាងជាតិពន្ធ និងវប្បធម៌ គឺជាការប្រកាន់ពូជសាសន៍ មិនត្រឹមត្រូវតាមលក្ខណៈវិទ្យាសាស្ត្រ គ្មានតំលៃគតិយុត្តិ មិនអាចទទួលយកបានខាងសីលធម៌ និងជាអំពើអយុត្តិធម៌សង្គម ។

*ដោយអះអាងជាថ្មីថា* ជនជាតិដើមភាគតិច ក្នុងការអនុវត្តសិទ្ធិរបស់ខ្លួន គប្បីគ្មានការរើសអើង ទោះជាក្នុងរូបភាពណាក៏ដោយ ។

*ដោយបារម្ភថា* ជនជាតិដើមភាគតិច ទទួលរងនូវអំពើអយុត្តិធម៌ជាប្រវត្តិសាស្ត្រ ដែលបណ្តាលមកពី ដូចជាការធ្វើ

អាណានិគមលើ និងការដកហូតយកដីធ្លី ដែនដី និងធនធាន របស់ពួកគេ ដែលរារាំងពួកគេ ក្នុងការប្រើប្រាស់សិទ្ធិរបស់ខ្លួន ជាពិសេសសិទ្ធិក្នុងការអភិវឌ្ឍតាមសេចក្តីត្រូវការ និងផលប្រយោជន៍របស់ខ្លួន។

*ដោយទទួលស្គាល់* នូវតម្រូវការជាបន្ទាន់ឱ្យគោរព និងលើកស្ទួយសិទ្ធិមានពីកំណើតរបស់ជនជាតិដើមភាគតិចដែលកើតចេញពីរចនាសម្ព័ន្ធនយោបាយ សេដ្ឋកិច្ច និង សង្គមកិច្ច និងពីវប្បធម៌ និងប្រពៃណីខាងជំនឿ ប្រវត្តិសាស្ត្រ និងទស្សនវិទ្យា ជាពិសេសសិទ្ធិរបស់ពួកគេលើដីធ្លី ដែនដី និងធនធានរបស់ពួកគេ។

*ដោយទទួលស្គាល់ផងដែរថា* តម្រូវការជាបន្ទាន់ឱ្យគោរព និងលើកស្ទួយសិទ្ធិជនជាតិដើមភាគតិចដែលមានចែងក្នុងសន្ធិសញ្ញា កិច្ចព្រមព្រៀង និងការសំរុះសំរួល ក្នុងន័យស្ថាបនាផ្សេងៗទៀត ជាមួយរដ្ឋនានា។

*ដោយស្វាគមន៍* ការពិតដែលថា ជនជាតិដើមភាគតិច កំពុងរៀបចំខ្លួន ដើម្បីអភិវឌ្ឍនយោបាយ សេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ និងដើម្បីបញ្ចប់ការរើសអើង និងការសង្កត់សង្កិនគ្រប់រូបភាព នៅពេលណាដែលកើតមាន។

*ដោយជឿជាក់ថា* ការគ្រប់គ្រងរបស់ជនជាតិដើមភាគតិចលើការអភិវឌ្ឍនានា ដែលមានឥទ្ធិពលលើជនជាតិដើមភាគតិច និងលើដីធ្លី ដែនដី និងធនធានរបស់ខ្លួន នឹងផ្តល់លទ្ធភាពឱ្យពួកគេ ក្នុងការរក្សា និងពង្រឹងស្ថាប័នវប្បធម៌ ប្រពៃណី និងលើកកំពស់ការអភិវឌ្ឍ ស្របតាមបំណងប្រាថ្នា និងសេចក្តីត្រូវការរបស់ខ្លួន។

*ដោយទទួលស្គាល់ដែរថា* ការគោរពចំពោះចំណេះដឹងវប្បធម៌និងការអនុវត្តជាប្រពៃណីរបស់ជនជាតិដើមភាគតិចរួមចំណែកក្នុងការអភិវឌ្ឍ ប្រកបដោយនិរន្តរភាព និងសមធម៌ និងការគ្រប់គ្រង បរិស្ថានយ៉ាងត្រឹមត្រូវ។

*ដោយបញ្ជាក់យ៉ាងច្បាស់ពី* ការរួមចំណែកដល់ការ មិនឱ្យមានវត្តមានយោធា នៅលើដីធ្លីនិងដែនដីរបស់ជនជាតិដើមភាគតិចដើម្បីនាំមកនូវសន្តិភាពការអភិវឌ្ឍ និងការរីកចំរើនខាងសេដ្ឋកិច្ច និងសង្គមកិច្ច ការយោគយល់គ្នា និងទំនាក់ទំនងជាមិត្តភាពជាមួយប្រជាជាតិ និងប្រជាជនលើពិភពលោក ។

*ដោយទទួលស្គាល់ជាពិសេស*នូវសិទ្ធិនៃក្រុមគ្រួសារ និងសហគមន៍ជនជាតិដើមភាគតិច ក្នុងការបន្តទទួលខុសត្រូវរួមចំពោះការចិញ្ចឹមបីបាច់ថែរក្សា ការបណ្តុះបណ្តាល ការអប់រំ និងសុខុមាលភាពកូនចៅរបស់ខ្លួន មានលក្ខណៈស្របគ្នានឹងសិទ្ធិកុមារ ។

*ដោយចាត់ទុកថា*សិទ្ធិទាំងឡាយដែលមានចែងក្នុងសន្ធិសញ្ញា កិច្ចព្រមព្រៀង និងកិច្ចចាត់ចែងក្នុងន័យស្ថាបនាដទៃទៀតរវាងរដ្ឋនានានិងជនជាតិដើមភាគតិចដែលនៅក្នុងស្ថានភាពខ្លះជាកង្វល់ ជាផលប្រយោជន៍ ជាការទទួលខុសត្រូវនិងមានចរិតជាអន្តរជាតិ ។

*ដោយចាត់ទុកដែរថា* សិទ្ធិសញ្ញា កិច្ចព្រមព្រៀងនិងកិច្ចចាត់ចែងក្នុងន័យស្ថាបនាដទៃទៀត និងទំនាក់ទំនងរបស់វាជាមូលដ្ឋានសំរាប់ភាពជាដៃគូដ៏រឹងមាំ រវាងជនជាតិដើមភាគតិច និងរដ្ឋនានា ។

*ដោយទទួលស្គាល់ថា* ធម្មនុញ្ញសហប្រជាជាតិកតិកា-សញ្ញាអន្តរជាតិស្តីពីសិទ្ធិសេដ្ឋកិច្ច សង្គមកិច្ច និង វប្បធម៌ និងកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋនិងសិទ្ធិនយោបាយ ព្រមទាំងសេចក្តីប្រកាសនិងកម្មវិធីសកម្មភាពទីក្រុងវីយែន បញ្ជាក់ពីសារៈសំខាន់ជាមូលដ្ឋាននៃសិទ្ធិស្វ័យសំរេចរបស់មនុស្សគ្រប់រូប ក្នុងស្មារតីនេះ មនុស្សទាំងអស់អាចសំរេចចិត្តដោយសេរីអំពីឋានៈនយោបាយរបស់ខ្លួន និងធ្វើការអភិវឌ្ឍសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌របស់ខ្លួនដោយសេរី ។

*ដោយចងចាំក្នុងចិត្តថា* មិនមានចំណុចណាមួយក្នុងសេចក្តីប្រកាសនេះ អាចត្រូវបានប្រើប្រាស់ ដើម្បីបដិសេធបុគ្គលណាម្នាក់នូវសិទ្ធិស្វ័យសំរេច ដែលបានអនុវត្តស្របតាមច្បាប់អន្តរជាតិឡើយ ។

*ដោយជឿជាក់ថា*ការទទួលស្គាល់សិទ្ធិជនជាតិដើមភាគតិច ក្នុងសេចក្តីប្រកាសនេះនឹងលើកកំពស់ទំនាក់ទំនងប្រកបដោយសុខដុម និងដោយសហការគ្នារវាងរដ្ឋនិងជនជាតិដើមភាគតិចដោយផ្អែកលើគោលការណ៍យុត្តិធម៌ ប្រជាធិបតេយ្យ ការគោរពសិទ្ធិមនុស្ស ការមិនរើសអើង និងសុចរិតភាព ។

*ដោយលើកទឹកចិត្ត*រដ្ឋទាំងអស់ឱ្យគោរពនិងអនុវត្តតាមកាតព្វកិច្ចរបស់ខ្លួន ប្រកបដោយប្រសិទ្ធភាព ដូចដែលអនុវត្តចំពោះជនជាតិដើមភាគតិច តាមលិខិតុបករណ៍អន្តរជាតិ ជាពិសេសលិខិតុបករណ៍ទាំងឡាយដែលពាក់ព័ន្ធនឹងសិទ្ធិមនុស្ស ដោយមានការពិគ្រោះយោបល់និងសហការគ្នាជាមួយបុគ្គលដែលពាក់ព័ន្ធ ។

*ដោយបញ្ជាក់ថា* អង្គការសហប្រជាជាតិ មានតួនាទីសំខាន់ដែលត្រូវបន្តអនុវត្ត ក្នុងការលើកកំពស់ និងការការពារសិទ្ធិជនជាតិដើមភាគតិច ។

*ដោយជឿថា* សេចក្តីប្រកាសនេះ គឺជាការបោះជំហានទៅមុខដ៏សំខាន់មួយ ក្នុងការទទួលស្គាល់ ការលើកស្ទួយ និងការការពារសិទ្ធិសេរីភាពជនជាតិដើមភាគតិច និងក្នុងការបង្កើតសកម្មភាពពាក់ព័ន្ធនៃប្រព័ន្ធអង្គការសហប្រជាជាតិនៅក្នុងវិស័យនេះ ។

*ដោយទទួលស្គាល់និងអះអាងជាថ្មីថា* ជនជាតិដើមភាគតិចគ្រប់រូប ដោយគ្មានការរើសអើងមានសិទ្ធិទទួលបានសិទ្ធិមនុស្សដែលបានទទួលស្គាល់ដោយច្បាប់អន្តរជាតិ *និងដោយទទួលស្គាល់ និងអះអាងជាថ្មីថា* ជនជាតិដើមភាគតិច មានកម្មសិទ្ធិសមូហភាពសំខាន់បំផុត និងមិនអាចដកហូតបានសំរាប់ជីវភាពរស់នៅ សុខុមាលភាព និងសំរាប់ការអភិវឌ្ឍដ៏សំខាន់ជាមនុស្ស ។

*ដោយទទួលស្គាល់ផងដែរថា* ជនជាតិដើមភាគតិចមានស្ថានភាពខុសគ្នា ពីតំបន់មួយទៅតំបន់មួយ និងខុសគ្នាពីប្រទេសមួយទៅប្រទេសមួយ និង *ថា*សារៈសំខាន់នៃលក្ខណៈ

ពិសេសនៃជាតិ និងតំបន់ ហើយសាវតាជាប្រវត្តិសាស្ត្រ និងវប្បធម៌ផ្សេងៗ គប្បីត្រូវបានលើកយកមកពិចារណា។

*សូមប្រកាសជាឧឡារិកថា*សេចក្តីប្រកាសរបស់អង្គការសហប្រជាជាតិស្តីពីសិទ្ធិជនជាតិដើមភាគតិច ខាងក្រោមនេះ ជាបទដ្ឋាននៃសមិទ្ធិផលដែលត្រូវបន្តអនុវត្ត តាមស្មារតី នៃភាពជាដៃគូ និងការគោរពគ្នាទៅវិញទៅមក។

## *មាត្រា ១ :*

ជនជាតិដើមភាគតិចជាសមូហភាពឬជាបុគ្គលមានសិទ្ធិទទួលបានយ៉ាងពេញលេញ នូវសិទ្ធិមនុស្ស និងសេរីភាព ជាមូលដ្ឋានដែលទទួលស្គាល់ដោយធម្មនុញ្ញសហប្រជាជាតិ សេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្សនិងច្បាប់សិទ្ធិមនុស្សអន្តរជាតិនានា។

## *មាត្រា ២ :*

ជនជាតិដើមភាគតិច និងបុគ្គលជាជនជាតិដើមភាគតិចមានសេរីភាព និងសមភាព ដូចប្រជាពលរដ្ឋ និងបុគ្គលដទៃ

ទៀត ព្រមទាំងមានសិទ្ធិរួចផុតពីការរើសអើងគ្រប់រូបភាព ក្នុងការអនុវត្តសិទ្ធិ ជាពិសេសដោយផ្អែកលើមូលហេតុនៃដើមកំណើត ឬអត្តសញ្ញាណរបស់ខ្លួន ជាជនជាតិដើមភាគតិច។

### *មាត្រា ៣ ៖*

ជនជាតិដើមភាគតិចមានសិទ្ធិស្វ័យសំរេច។ តាមស្មារតីនៃសិទ្ធិនេះ ជនជាតិដើមភាគតិច ធ្វើសេចក្តីសំរេចចិត្ត អំពីឋានៈនយោបាយរបស់ខ្លួនដោយសេរី និងធ្វើការអភិវឌ្ឍសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌របស់ខ្លួនដោយសេរី។

### *មាត្រា ៤ ៖*

ជនជាតិដើមភាគតិច ក្នុងការអនុវត្តសិទ្ធិស្វ័យសំរេចរបស់ខ្លួនមានសិទ្ធិគ្រប់គ្រងដោយខ្លួនឯងឬដោយស្វ័យភាពលើបញ្ហាទាំងឡាយ ដែលទាក់ទងនឹងកិច្ចការផ្ទៃក្នុង និងកិច្ចការ នៅមូលដ្ឋានរបស់ខ្លួនព្រមទាំងវិធីសាស្ត្រនិងមធ្យោបាយផ្សេងៗសំរាប់ផ្តល់ហិរញ្ញវត្ថុ ដល់ដំណើរការស្វ័យភាពរបស់ខ្លួន។

***មាត្រា ៥ :***

ជនជាតិដើមភាគតិចមានសិទ្ធិរក្សា និងពង្រឹងស្ថាប័ននយោបាយ ច្បាប់ សេដ្ឋកិច្ច សង្គមកិច្ច និង វប្បធម៌ផ្សេងៗរបស់ខ្លួន ទន្ទឹមនេះក៏មានសិទ្ធិចូលរួមយ៉ាងពេញលេញ ក្នុងជីវភាពនយោបាយ សេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌របស់រដ្ឋផងដែរ តាមការជ្រើសរើសរបស់ពួកគេ។

***មាត្រា ៦ :***

ជនជាតិដើមភាគតិចគ្រប់រូបមានសិទ្ធិទទួលបានសញ្ជាតិ។

***មាត្រា ៧ :***

១. ជនជាតិដើមភាគតិច មានសិទ្ធិរស់រានមានជីវិតបូរណភាពរូបកាយ និងបញ្ញាស្មារតី មានសេរីភាព និងសន្តិសុខផ្ទាល់ខ្លួន។

២. ជនជាតិដើមភាគតិចមានសិទ្ធិសមូហភាពក្នុងការរស់នៅប្រកបដោយសេរីភាព សន្តិភាព និងសន្តិសុខជាប្រជា

ពលរដ្ឋមានលក្ខណៈផ្សេងពីគេហើយនិងមិនត្រូវជាកម្មវត្ថុនៃអំពើប្រល័យពូជសាសន៍ ឬអំពើហឹង្សាណាមួយឡើយ រួមទាំងការបំបែកកុមារ ដោយបង្ខំចេញពីក្រុមមួយ ទៅដាក់ក្រុមមួយផ្សេងទៀត។

***មាត្រា ៨ :***

១. ជនជាតិដើមភាគតិច និងបុគ្គលជាជនជាតិដើមភាគតិចមានសិទ្ធិមិនស្ថិតក្នុងកម្មវត្ថុនៃការបង្ខំឱ្យរស់នៅលាយឡំក្នុងសហគមន៍ផ្សេង ឬការបំផ្លាញវប្បធម៌របស់ខ្លួនឡើយ។

២. រដ្ឋទាំងឡាយ ត្រូវផ្តល់យន្តការការពារ និងដោះស្រាយ ប្រកបដោយប្រសិទ្ធភាពចំពោះ :

ក. អំពើណាមួយដែលមានបំណង ឬមានឥទ្ធិពលដល់ការដកហូតពីពួកគេនូវបូរណភាពជាប្រជាពលរដ្ឋមានលក្ខណៈផ្សេងពីគេ ឬការដកហូតតម្លៃវប្បធម៌ ឬអត្តសញ្ញាណជាតិពន្ធុរបស់ពួកគេ។

ខ. អំពើណាមួយដែលមានបំណង ឬមានឥទ្ធិពល ដល់ការដកហូតពីពួកគេ នូវដីធ្លី ដែនដី ឬធនធានរបស់ពួកគេ ។

គ. រូបភាពណាមួយនៃការជម្លៀសជនជាតិដើមភាគតិចដោយបង្ខំ ដែលមានគោលបំណង ឬមានឥទ្ធិពលដល់ការរំលោភ ឬការធ្វើឱ្យអន្តរាយដល់សិទ្ធិរបស់ពួកគេ ។

ឃ.រូបភាពណាមួយនៃការបង្ខំឱ្យរស់នៅលាយឡំក្នុងសហគមន៍ផ្សេង ឬសមាហរណកម្ម ។

ង. រូបភាពណាមួយនៃការឃោសនា ដែលបានរៀបចំឡើងដើម្បីជំរុញ ឬញុះញង់ឱ្យមានការរើសអើងជាតិសាសន៍ ឬជាតិពន្ធុ សំដៅប្រឆាំងជនជាតិដើមភាគតិច ។

## *មាត្រា ៩ :*

ជនជាតិដើមភាគតិច និងបុគ្គលជាជនជាតិដើមភាគតិចមានសិទ្ធិស្ថិតនៅជាសមាជិក សហគមន៍ជនជាតិដើមភាគតិច ឬសង្គមជាតិ ស្របតាមប្រពៃណី និងទំនៀមទំលាប់របស់

សហគមន៍ និងសង្គមជាតិពាក់ព័ន្ធ។ គ្មានការរើសអើងណាមួយ កើតឡើងដោយសារតែការប្រើប្រាស់សិទ្ធិនេះឡើយ។

### *មាត្រា ១០ ៖*

ជនជាតិដើមភាគតិច មិនត្រូវបានគេបណ្តេញដោយបង្ខំចេញពីដីធ្លីឬដែនដីរបស់ខ្លួនឡើយ។ ការតាំងលំនៅថ្មីមិនត្រូវធ្វើដោយគ្មានការយល់ព្រមដោយសេរី និងដោយមិនបានប្រាប់ឱ្យដឹងជាមុនដល់ជនជាតិដើមភាគតិចពាក់ព័ន្ធ និងបន្ទាប់ពីមានការព្រមព្រៀងលើសំណងត្រឹមត្រូវ និងយុត្តិធម៌នោះឡើយ ហើយបើសិនជាធ្វើទៅបាន ត្រូវដាក់ឱ្យមាននូវជំរើសនៃការវិលត្រលប់មកកាន់ដីធ្លី ឬដែនដីរបស់ខ្លួនវិញ។

### *មាត្រា ១១ ៖*

១. ជនជាតិដើមភាគតិចមានសិទ្ធិប្រតិបត្តិ និងធ្វើឱ្យរស់រវើកឡើងវិញនូវប្រពៃណីនិងទំនៀមទំលាប់ជាវប្បធម៌របស់ខ្លួន។ សិទ្ធិនេះរួមមានទាំងសិទ្ធិក្នុងការថែរក្សា ការពារ និង

អភិវឌ្ឍន៍អ្វីៗដែលបង្ហាញពីអត្តសញ្ញាណវប្បធម៌របស់ខ្លួន ដែលមានពីអតីតកាល បច្ចុប្បន្ន និងអនាគត ដូចជាតំបន់បុរាណវិទ្យា និងតំបន់ប្រវត្តិសាស្ត្រ បុរាណវត្ថុ រចនាបថ ពិធីបុណ្យ បច្ចេកវិទ្យា និងសិល្បៈ ទស្សនីយភាព និងការសំដែងសិល្បៈ និងអក្សរសាស្ត្រ។

២. រដ្ឋទាំងឡាយ ត្រូវផ្តល់ឱ្យមាននូវដំណោះស្រាយតាមរយៈយន្តការមានប្រសិទ្ធភាព ដែលរួមមានទាំងបដិទានដោយបានរៀបចំបង្កើតឡើងជាមួយជនជាតិដើមភាគតិចចំពោះកម្មសិទ្ធិវប្បធម៌ បញ្ញា សាសនា និងជំនឿរបស់ពួកគេ ដែលត្រូវបានដកហូត ដោយគ្មានការយល់ព្រមដោយសេរី និងដោយមិនបានប្រាប់ឱ្យដឹងជាមុន ឬដែលរំលោភលើច្បាប់ប្រពៃណី និងទំនៀម ទំលាប់របស់ពួកគេ។

## ***មាត្រា ១២ :***

១. ជនជាតិដើមភាគតិច មានសិទ្ធិបង្ហាញ ប្រតិបត្តិ អភិវឌ្ឍ និងបង្រៀនប្រពៃណីខាងជំនឿ និងសាសនារបស់

ខ្លួន ទំនៀមទំលាប់និងពិធីបុណ្យផ្សេងៗ ហើយមានសិទ្ធិរក្សាការពារ និងមានសិទ្ធិជាឯកជនក្នុងការប្រើប្រាស់ទីកន្លែងសាសនា និងវប្បធម៌របស់ខ្លួន។ មានសិទ្ធិប្រើប្រាស់ និងគ្រប់គ្រងវត្ថុសំរាប់ពិធីបុណ្យនានា និងមានសិទ្ធិនាំអដ្ឋិធាតុត្រលប់មកកាន់ដែនដីកំណើតរបស់ពួកគេ។

២. រដ្ឋនានា ត្រូវព្យាយាមបង្កលក្ខណៈងាយស្រួល ដល់ការទទួលយកមកប្រើប្រាស់នូវវត្ថុសំរាប់ពិធីបុណ្យ និង/ឬនាំត្រលប់មកកាន់ដែនដីកំណើតវិញនូវវត្ថុសំរាប់ពិធីបុណ្យដែលជាភោគទ្រព្យរបស់ពួកគេ តាមរយៈយន្តការយុត្តិធម៌ តម្លាភាព និងប្រសិទ្ធភាពដែលយន្តការនេះបានបង្កើតឡើងរួមគ្នាជាមួយជនជាតិដើមភាគតិចពាក់ព័ន្ធ។

## *មាត្រា ១៣ ៖*

១. ជនជាតិដើមភាគតិច មានសិទ្ធិធ្វើឱ្យរស់រវើកឡើងវិញ ប្រើប្រាស់អភិវឌ្ឍ និងផ្ទេរឱ្យកូនចៅជំនាន់ក្រោយនូវប្រវត្តិសាស្ត្រ ភាសា ច្បាប់ទំលាប់ ទស្សនវិជ្ជា ប្រព័ន្ធនៃការ

សរសេរ និងអក្សរសាស្ត្រ ព្រមទាំងធ្វើការកំណត់ឈ្មោះ និងរក្សាឈ្មោះរបស់ពួកគេដោយខ្លួនឯង សំរាប់សហគមន៍ ទីកន្លែង និងបុគ្គល ។

២. រដ្ឋនានាត្រូវចាត់វិធានការប្រកបដោយប្រសិទ្ធភាពដើម្បីធានាថាសិទ្ធិទាំងនេះ ត្រូវបានការពារ និងធានាផងដែរថា ជនជាតិដើមភាគតិចអាចយល់ដឹងនិងត្រូវធ្វើឱ្យបានយល់ដឹងអំពីដំណើរការនយោបាយ ច្បាប់និងរដ្ឋបាល ហើយប្រសិនជាចាំបាច់ត្រូវធ្វើឡើង តាមរយៈការបកប្រែ ឬតាមមធ្យោបាយសមស្របដទៃទៀត ។

***មាត្រា ១៤ :***

១. ជនជាតិដើមភាគតិចមានសិទ្ធិបង្កើតនិងគ្រប់គ្រងស្ថាប័ន និងប្រព័ន្ធអប់រំរបស់ខ្លួន ដោយផ្តល់ការអប់រំជាភាសារបស់ខ្លួនផ្ទាល់ ក្នុងលក្ខណៈសមស្របនឹងវិធីសាស្ត្រ តាមវប្បធម៌នៃការបង្រៀន និងរៀនសូត្ររបស់ពួកគេ ។

២. បុគ្គលជាជនជាតិដើមភាគតិចគ្រប់រូប ជាពិសេសកុមារមានសិទ្ធិទទួលបានការអប់រំនៅគ្រប់កំរិត និងគ្រប់រូបភាពនៃការអប់រំរបស់រដ្ឋ ដោយគ្មានការរើសអើងឡើយ។

៣. រដ្ឋទាំងឡាយ ដោយសហការជាមួយជនជាតិដើមភាគតិច ត្រូវចាត់វិធានការប្រកបដោយប្រសិទ្ធភាព ដើម្បីឱ្យបុគ្គលជាជនជាតិដើមភាគតិច ជាពិសេសកុមារ រួមទាំងអ្នកដែលរស់នៅក្រៅសហគមន៍ផង មានសិទ្ធិទទួលបានការអប់រំទៅតាមវប្បធម៌ផ្ទាល់ខ្លួនរបស់ពួកគេ និងត្រូវផ្តល់ការអប់រំនោះ ជាភាសារបស់ពួកគេ ប្រសិនជាអាចធ្វើបាន។

***មាត្រា ១៥ :***

១. ជនជាតិដើមភាគតិច មានសិទ្ធិចំពោះភាពថ្លៃថ្នូរ និងភាពចំរុះនៃវប្បធម៌ ប្រពៃណី ប្រវត្តិសាស្ត្រ និងបំណងប្រាថ្នាដែលត្រូវឆ្លុះបញ្ចាំងយ៉ាងសមស្របនៅក្នុងការអប់រំ និងព័ត៌មានសាធារណៈ។

២. រដ្ឋទាំងឡាយ ត្រូវចាត់វិធានការប្រកបដោយប្រសិទ្ធភាព ដោយការពិគ្រោះយោបល់និងសហការជាមួយជនជាតិដើមភាគតិចពាក់ព័ន្ធ ដើម្បីប្រយុទ្ធប្រឆាំងនឹងការប្រកាន់ពូជសាសន៍ និងលុបបំបាត់ការរើសអើង ព្រមទាំងលើកកំពស់ការអធ្យាស្រ័យគ្នា ការយោគយល់គ្នា និងទំនាក់ទំនងល្អ ក្នុងចំណោមជនជាតិដើមភាគតិច និងនៅគ្រប់ផ្នែកនៃសង្គម ។

## *មាត្រា ១៦ :*

១. ជនជាតិដើមភាគតិច មានសិទ្ធិបង្កើតប្រព័ន្ធផ្សព្វ-ផ្សាយដោយប្រើភាសារបស់ខ្លួន និងមានសិទ្ធិប្រើប្រាស់ តាមគ្រប់រូបភាពនៃប្រព័ន្ធផ្សព្វផ្សាយដែលមិនមែនជារបស់ជនជាតិដើមភាគតិច ដោយគ្មានការរើសអើងឡើយ ។

២. រដ្ឋទាំងឡាយ ត្រូវចាត់វិធានការប្រកបដោយប្រសិទ្ធភាព ដើម្បីធានាថាប្រព័ន្ធផ្សព្វផ្សាយរបស់រដ្ឋពិតជាឆ្លុះបញ្ចាំងនូវភាពចំរុះនៃវប្បធមិរបស់ជនជាតិដើមភាគតិច ។ ដោយភាពមិនលំអៀង ដើម្បីធានាដល់សេរីភាពយ៉ាងពេញលេញ

ក្នុងការសំដែងមតិ រដ្ឋទាំងឡាយ គប្បីលើកទឹកចិត្តឱ្យមានប្រព័ន្ធផ្សព្វផ្សាយ ដែលជាកម្មសិទ្ធិឯកជន ដើម្បីឆ្លើយតបយ៉ាងពេញលេញចំពោះភាពចំរុះនៃវប្បធម៌ជនជាតិដើមភាគតិច ។

## *មាត្រា ១៧ :*

១. ជនជាតិដើមភាគតិច និងបុគ្គលជាជនជាតិដើមភាគតិចគ្រប់រូប មានសិទ្ធិទទួលបានយ៉ាងពេញលេញ នូវសិទ្ធិគ្រប់យ៉ាង ដែលមានចែងក្នុងច្បាប់ការងារអន្តរជាតិ និងច្បាប់ការងារជាតិជាធរមាន ។

២. រដ្ឋទាំងឡាយក្នុងការពិគ្រោះយោបល់ និងសហការជាមួយជនជាតិដើមភាគតិច ត្រូវចាត់វិធានការ ជាក់ស្តែងដើម្បីការពារកុមារជាជនជាតិដើមភាគតិចពីការកេងប្រវ័ញ្ចផ្នែកសេដ្ឋកិច្ច ពីការធ្វើការងារណាដែលអាចមានគ្រោះថ្នាក់ ឬដែលអាចប៉ះពាល់ដល់ការសិក្សារបស់កុមារ ឬដែលអាចមានគ្រោះថ្នាក់ដល់សុខភាព ឬការអភិវឌ្ឍខាងរាងកាយ ផ្លូវ

ចិត្ត ស្មារតី សីលធម៌ ឬសង្គម ដោយត្រូវគិតទៅដល់ភាពងាយរងគ្រោះ ជាពិសេសរបស់កុមារ និងអំពីសារៈសំខាន់នៃការអប់រំ ដើម្បីពង្រឹងសមត្ថភាពពួកគេ។

៣. បុគ្គលជាជនជាតិដើមភាគតិចគ្រប់រូប មានសិទ្ធិមិនស្ថិតក្រោមលក្ខខណ្ឌនៃការរើសអើងណាមួយនៃពលកម្ម ដូចជាការងារ ឬប្រាក់បៀវត្សរ៍ជាដើម។

***មាត្រា ១៨ :***

ជនជាតិដើមភាគតិចមានសិទ្ធិចូលរួមក្នុងការធ្វើសេចក្តីសំរេចចិត្តលើរាល់បញ្ហាដែលអាចប៉ះពាល់ដល់សិទ្ធិរបស់ពួកគេតាមរយៈតំណាងដែលជ្រើសតាំងដោយពួកគេផ្ទាល់ ស្របតាមនីតិវិធីរបស់ខ្លួន ក៏ដូចជាមានសិទ្ធិរក្សា និងបង្កើតស្ថាប័នជនជាតិដើមភាគតិចដែលមានតួនាទីធ្វើសេចក្តីសំរេចចិត្តនានា។

***មាត្រា ១៩ :***

រដ្ឋទាំងឡាយត្រូវពិគ្រោះយោបល់ និងសហការ ដោយ

សុចរិតជាមួយជនជាតិដើមភាគតិចពាក់ព័ន្ធតាមរយៈស្ថាប័នតំណាងរបស់ខ្លួន ដើម្បីទទួលបានការយល់ព្រមដោយសេរី និងដោយបានប្រាប់ឱ្យដឹងជាមុន មុននឹងអនុម័ត និងអនុវត្តវិធានការច្បាប់ ឬវិធានការរដ្ឋបាល ដែលអាចប៉ះពាល់ដល់ជនជាតិដើមភាគតិច។

### *មាត្រា ២០ :*

១. ជនជាតិដើមភាគតិចមានសិទ្ធិរក្សា និងបង្កើតប្រព័ន្ធ ឬស្ថាប័ននយោបាយ សេដ្ឋកិច្ច និងសង្គមកិច្ច ដើម្បីធានាបាននូវមធ្យោបាយក្នុងការចិញ្ចឹមជីវិត និងការអភិវឌ្ឍផ្ទាល់ខ្លួនរបស់ពួកគេ និងដើម្បីចូលរួមដោយសេរីនៅគ្រប់សកម្មភាពជាប្រពៃណី និងសេដ្ឋកិច្ចផ្សេងៗទៀត។

២. ជនជាតិដើមភាគតិច ដែលត្រូវគេដកហូតមធ្យោបាយក្នុងការចិញ្ចឹមជីវិត និងការអភិវឌ្ឍមានសិទ្ធិទទួលបាននូវដំណោះស្រាយត្រឹមត្រូវ និងយុត្តិធម៌។

***មាត្រា ២១ ៖***

១. ជនជាតិដើមភាគតិច ដោយគ្មានការរើសអើង មានសិទ្ធិក្នុងការលើកកំពស់លក្ខខណ្ឌសេដ្ឋកិច្ច និងសង្គមកិច្ច រួមមានដូចជា ក្នុងវិស័យអប់រំ ការងារ ការបណ្តុះបណ្តាលវិជ្ជាជីវៈ និងការបណ្តុះបណ្តាលឡើងវិញ លំនៅដ្ឋាន អនាម័យ សុខភាព និងសន្តិសុខសង្គម។

២. រដ្ឋទាំងឡាយត្រូវចាត់វិធានការប្រកបដោយប្រសិទ្ធភាព ហើយប្រសិនជាចាំបាច់ ត្រូវចាត់វិធានការពិសេសដើម្បីធានាដល់ការបន្តលើកកំពស់លក្ខខណ្ឌសេដ្ឋកិច្ច និងសង្គមកិច្ចរបស់ខ្លួន។ រដ្ឋត្រូវយកចិត្តទុកដាក់ ជាពិសេសលើសិទ្ធិ និងសេចក្តីត្រូវការពិសេសរបស់ជនជាតិដើមភាគតិច ដែលជាមនុស្សចាស់ ស្ត្រី យុវជន កុមារ និងជនពិការ។

***មាត្រា ២២ ៖***

១. ក្នុងការអនុវត្តសេចក្តីប្រកាសនេះ រដ្ឋត្រូវយកចិត្តទុកដាក់ជាពិសេសលើសិទ្ធិ និងសេចក្តីត្រូវការពិសេសរបស់

ជនជាតិដើមភាគតិច ដែលជាមនុស្សចាស់ ស្ត្រី យុវជន កុមារ និងជនពិការ ។

២. រដ្ឋទាំងឡាយ ត្រូវចាត់វិធានការ ដោយសហការជាមួយជនជាតិដើមភាគតិចដើម្បីធានាថា ស្ត្រីនិងកុមារជនជាតិដើមភាគតិច ទទួលបានការការពារ និងការធានាបានទាំងស្រុងប្រឆាំងនឹងអំពើហឹង្សា និងការរើសអើងគ្រប់រូបភាព ។

***មាត្រា ២៣ :***

ជនជាតិដើមភាគតិចមានសិទ្ធិសំរេច និងបង្កើតផែនការអាទិភាព និងយុទ្ធសាស្ត្រនានា សំរាប់អនុវត្តសិទ្ធិរបស់ខ្លួនចំពោះការអភិវឌ្ឍ។ ជាពិសេស ជនជាតិដើមភាគតិច មានសិទ្ធិចូលរួមយ៉ាងសកម្មក្នុងការអភិវឌ្ឍ និងការសំរេចលើកម្មវិធីសុខភាព លំនៅដ្ឋាន និងកម្មវិធីសេដ្ឋកិច្ចនិងសង្គមកិច្ចផ្សេងៗទៀត ដែលប៉ះពាល់ដល់ពួកគេ ហើយប្រសិនជាអាចធ្វើបាន ត្រូវគ្រប់គ្រងកម្មវិធីបែបនោះ តាមរយៈស្ថាប័នផ្ទាល់របស់ពួកគេ ។

## *មាត្រា ២៤ ៖*

១. ជនជាតិដើមភាគតិចមានសិទ្ធិក្នុងការប្រើប្រាស់ឱសថបុរាណរបស់ខ្លួន និងមានសិទ្ធិរក្សាវិធីប្រតិបត្តិផ្នែកសុខភាព រួមទាំងការអភិរក្សរុក្ខជាតិ សត្វ និងរ៉ែ ដែលចាំបាច់សំរាប់ធ្វើឱសថ។ ជនជាតិដើមភាគគ្រប់រូប ក៏មានសិទ្ធិទទួលបាននូវសេវាកម្មសង្គមកិច្ច និងសុខាភិបាលគ្រប់បែបយ៉ាង ដោយគ្មានការរើសអើងឡើយ ។

២. ជនជាតិដើមភាគតិចគ្រប់រូប មានសិទ្ធិស្មើគ្នាចំពោះបទដ្ឋានសុខភាពខាងរាងកាយនិងផ្លូវចិត្តក៏រិតខ្ពស់បំផុត ។ រដ្ឋត្រូវចាត់វិធានការចាំបាច់ ក្នុងគោលបំណងធ្វើឱ្យសំរេចបានយ៉ាងរីកចំរើនដល់ការទទួលបានពេញលេញនូវសិទ្ធិទាំងនេះ ។

## *មាត្រា ២៥ ៖*

ជនជាតិដើមភាគតិច មានសិទ្ធិរក្សា និងពង្រឹងទំនាក់ទំនងខាងជំនឿសាសនារបស់ពួកគេ ជាមួយនឹងដីធ្លី ដែនដី ដែនទឹក និងឆ្នេរសមុទ្រ និងធនធានផ្សេងៗទៀតដែលពួកគេ

មាន ឬបានកាន់កាប់ និងបានប្រើប្រាស់ជាប្រពៃណី និងដើម្បីលើកកំពស់ការទទួលខុសត្រូវរបស់ពួកគេ ចំពោះកូនចៅជំនាន់ក្រោយ ។

***មាត្រា ២៦ :***

១. ជនជាតិដើមភាគតិចមានសិទ្ធិលើដីធ្លី ដែនដី និងធនធានដែលពួកគេមាន ឬបានកាន់កាប់ ឬបានប្រើប្រាស់ ឬបានទទួលជាប្រពៃណី ។

២. ជនជាតិដើមភាគតិច មានសិទ្ធិជាម្ចាស់ ប្រើប្រាស់ អភិវឌ្ឍន៍ និងគ្រប់គ្រងដីធ្លី ដែនដី និងធនធានដែលខ្លួនមាន ដោយសារហេតុផលនៃកម្មសិទ្ធិជាប្រពៃណី ឬការកាន់កាប់ ឬការប្រើប្រាស់ជាប្រពៃណីដទៃទៀត ក៏ដូចជាអ្វី១ផ្សេងទៀត ដែលពួកគេមាន ។

៣. រដ្ឋត្រូវទទួលស្គាល់ និងការពារតាមផ្លូវច្បាប់ ចំពោះដីធ្លី ដែនដី និងធនធាននានា ។ ការទទួលស្គាល់បែបនេះ ត្រូវប្រព្រឹត្តទៅដោយគោរពយ៉ាងត្រឹមត្រូវចំពោះទំនៀមទំលាប់

ប្រពៃណី និងប្រព័ន្ធកាន់កាប់ដីធ្លី របស់ជនជាតិដើមភាគតិចពាក់ព័ន្ធ។

***មាត្រា ២៧ :***

រដ្ឋទាំងឡាយ ដោយសហការជាមួយជនជាតិដើមភាគតិចពាក់ព័ន្ធត្រូវបង្កើត និងអនុវត្តកិច្ចដំណើរការប្រកបដោយភាពយុត្តិធម៌ ឯករាជ្យ មិនលំអៀង ដោយចំហ និងតម្លាភាព ដោយទទួលស្គាល់យ៉ាងត្រឹមត្រូវចំពោះច្បាប់ ប្រពៃណី ទំនៀមទំលាប់ និងប្រព័ន្ធកាន់កាប់ដីធ្លីរបស់ជនជាតិដើមភាគតិច ទទួលស្គាល់ និងវិនិច្ឆ័យសិទ្ធិរបស់ជនជាតិដើមភាគតិច ដែលទាក់ទងនឹងដីធ្លី ទឹកដី និងធនធាននានា រួមទាំងអ្វីៗដែលពួកគេមាន ឬបានកាន់កាប់ ឬបានប្រើប្រាស់ជាប្រពៃ ណី។ ជនជាតិដើមភាគតិចត្រូវមានសិទ្ធិចូលរួមក្នុងកិច្ចដំណើរការនេះ។

***មាត្រា ២៨ :***

១. ជនជាតិដើមភាគតិច មានសិទ្ធិទទួលបានដំណោះស្រាយតាមមធ្យោបាយផ្សេងៗ ដែលរួមទាំងការធ្វើឱ្យដូច

ដើមវិញ ឬប្រសិនជាករណីនេះមិនអាចធ្វើទៅបាន ត្រូវផ្តល់សំណងត្រឹមត្រូវ យុត្តិធម៌ និងស្មើភាពសំរាប់ដីធ្លី ទឹកដី និងធនធាននានា ដែលជនជាតិដើមភាគតិចមាន ឬបានកាន់កាប់ ឬបានប្រើប្រាស់ជាប្រពៃណី ហើយដែលត្រូវបានដកហូតយក បានកាន់កាប់ បានប្រើប្រាស់ ឬបានធ្វើឱ្យអន្តរាយដោយគ្មានការយល់ព្រមដោយសេរី និងដោយមិនបានប្រាប់ឱ្យដឹងជាមុន ដល់ជនជាតិដើមភាគតិចពាក់ព័ន្ធ។

២. លុះត្រាតែមានការយល់ព្រមដោយសេរីពីជនជាតិដើមភាគតិចពាក់ព័ន្ធ បើមិនដូច្នេះទេ សំណងត្រូវធ្វើឡើងក្នុងរូបភាពជាដីធ្លី ដែនដី និងធនធានដែលមានតម្លៃស្មើនឹងគុណភាព ទំហំ ឋានៈផ្លូវច្បាប់ ឬសំណង ជាប្រាក់ឬដំណោះស្រាយសមរម្យផ្សេងទៀត។

***មាត្រា ២៩ :***

១. ជនជាតិដើមភាគតិចមានសិទ្ធិក្នុងការអភិរក្ស និងការការពារបរិស្ថាន និងសមត្ថភាពផលិតកម្មលើដីធ្លី ដែនដី

និងធនធាននានារបស់ពួកគេ។ រដ្ឋត្រូវបង្កើត និងអនុវត្តកម្មវិធីជំនួយ សំរាប់ជនជាតិដើមភាគតិច ក្នុងការអភិរក្ស និងការការពារបែបនេះ ដោយគ្មានការរើសអើងឡើយ។

២. រដ្ឋទាំងឡាយត្រូវចាត់វិធានការប្រកបដោយប្រសិទ្ធភាព ដើម្បីធានាមិនឱ្យមានឃ្លាំងដាក់សម្ភារៈដែលបង្កគ្រោះថ្នាក់ ឬបោះចោលសម្ភារៈបែបនេះនៅលើដីធ្លី ឬដែនដីរបស់ជនជាតិដើមភាគតិច ដោយគ្មានការយល់ព្រមដោយសេរី ឬដោយស្ម័គ្រចិត្តជាមុន ពីជនជាតិដើមភាគតិចពាក់ព័ន្ធ។

៣. រដ្ឋទាំងឡាយ ក៏ត្រូវចាត់វិធានការប្រកបដោយប្រសិទ្ធភាពតាមការចាំបាច់ដើម្បីធានាថាកម្មវិធីពិនិត្យ តាមដាន ថែរក្សា និងព្យាបាលសុខភាពជនជាតិដើមភាគតិច ដែលបានបង្កើត និងអនុវត្តដោយជនជាតិដើមភាគតិច ដែលរងផលប៉ះពាល់ដោយសារសម្ភារៈបែបនេះ ត្រូវបានអនុវត្តយ៉ាងត្រឹមត្រូវ។

## មាត្រា ៣០ ៖

១. សកម្មភាពយោធា មិនត្រូវអនុញ្ញាតឱ្យមាននៅលើដីធ្លី ឬដែនដីរបស់ជនជាតិដើមភាគតិចឡើយ ប្រសិនជាគ្មានភស្តុតាងបញ្ជាក់ថា មានការគំរាមកំហែងធ្ងន់ធ្ងរ ដល់ផលប្រយោជន៍សាធារណៈពាក់ព័ន្ធទេ ឬប្រសិនជាគ្មានការយល់ព្រមដោយសេរី ឬតាមការស្នើសុំពីជនជាតិដើមភាគតិចពាក់ព័ន្ធទេនោះ ។

២. រដ្ឋទាំងឡាយ ត្រូវធ្វើការពិគ្រោះយោបល់ប្រកបដោយប្រសិទ្ធភាពជាមួយជនជាតិដើមភាគតិចពាក់ព័ន្ធ តាមរយៈនីតិវិធីសមស្រប ហើយជាពិសេស តាមរយៈស្ថាប័នតំណាងរបស់ពួកគេ មុននឹងប្រើប្រាស់ដីធ្លី ឬដែនដីរបស់ពួកគេ សំរាប់សកម្មភាពយោធា ។

## មាត្រា ៣១ ៖

១. ជនជាតិដើមភាគតិចមានសិទ្ធិរក្សា គ្រប់គ្រង ការពារ និងអភិវឌ្ឍមរតកវប្បធម៌ ចំណេះដឹងជាប្រពៃណី និងការសំដែងនូវវប្បធម៌ជាប្រពៃណី ក៏ដូចជាការបង្ហាញឱ្យគេដឹង

អំពីវិទ្យាសាស្ត្រ បច្ចេកវិទ្យានិងវប្បធម៌របស់ពួកគេ រួមមាន ទាំងធនធានមនុស្ស និងធនធានពន្ធុ គ្រាប់ពូជ ឱសថ ចំណេះដឹងខាងរុក្ខជាតិ និងសត្វព្រៃ ប្រពៃណីនិយាយផ្ទាល់មាត់ អក្សរសាស្ត្រ រចនាបថ កីឡា និងល្បែងប្រពៃណី ព្រមទាំងសិល្បៈ សំដែង និងទស្សនីយភាព។ ជនជាតិដើមភាគតិច ក៏មានសិទ្ធិរក្សា គ្រប់គ្រង ការពារ និងបង្កើតឡើងនូវកម្មសិទ្ធិបញ្ញារបស់ខ្លួន លើមរតកវប្បធម៌ ចំណេះដឹងជាប្រពៃណីនិងការសំដែងវប្បធម៌ប្រពៃណី។

២. រដ្ឋទាំងឡាយ ដោយសហការជាមួយជនជាតិដើមភាគតិច ត្រូវចាត់វិធានការប្រកបដោយប្រសិទ្ធភាព ដើម្បីទទួលស្គាល់ និងការពារដល់ការអនុវត្តសិទ្ធិទាំងនេះ។

***មាត្រា ៣២ :***

១. ជនជាតិដើមភាគតិចមានសិទ្ធិសំរេច និងបង្កើតផែនការអាទិភាព និងយុទ្ធសាស្ត្រនានាសំរាប់ការអភិវឌ្ឍ ឬការប្រើប្រាស់ដីធ្លី ឬដែនដី និងធនធានផ្សេងទៀតរបស់ពួកគេ។

២. រដ្ឋទាំងឡាយ ត្រូវពិគ្រោះយោបល់ និងសហការដោយសុចរិតជាមួយជនជាតិដើមភាគតិចពាក់ព័ន្ធ តាមរយៈស្ថាប័នតំណាងរបស់ខ្លួនផ្ទាល់ ដើម្បីទទួលបានការយល់ព្រមដោយសេរី និងដោយបានប្រាប់ឱ្យដឹង មុននឹងអនុម័តលើគំរោងណាមួយ ដែលប៉ះពាល់ដល់ដីធ្លី ឬដែនដី និងធនធាននានារបស់ពួកគេ ជាពិសេស គំរោងទាំងឡាយដែលទាក់ទងនឹងការអភិវឌ្ឍ ការប្រើប្រាស់ និងការធ្វើអាជីវកម្មរ៉ែ ដែនទឹក ឬធនធានផ្សេងៗទៀត។

៣. រដ្ឋទាំងឡាយ ត្រូវផ្តល់យន្តការប្រកបដោយប្រសិទ្ធភាព ដើម្បីជួសជុលការខូចខាតឱ្យបានត្រឹមត្រូវ និងយុត្តិធម៌សំរាប់សកម្មភាពទាំងនេះ និងត្រូវចាត់វិធានការសមស្របដើម្បីបន្ថយផលប៉ះពាល់ធ្ងន់ធ្ងរដល់បរិស្ថាន សេដ្ឋកិច្ច សង្គមកិច្ច វប្បធម៌ ឬស្មារតី។

### *មាត្រា ៣៣ ៖*

១. ជនជាតិដើមភាគតិច មានសិទ្ធិក្នុងការកំណត់អត្តសញ្ញាណ ឬសមាជិកភាពរបស់ខ្លួនផ្ទាល់ ស្របតាមទំនៀមទំលាប់ និងប្រពៃណីរបស់ពួកគេ។ ការនេះមិនធ្វើឱ្យបុគ្គលជនជាតិដើមភាគតិច បាត់បង់សិទ្ធិក្នុងការទទួលបានសញ្ជាតិពីរដ្ឋដែលខ្លួនរស់នៅឡើយ។

២. ជនជាតិដើមភាគតិច មានសិទ្ធិក្នុងការកំណត់រចនាសម្ព័ន្ធ និងជ្រើសរើសសមាជិកភាពនៃស្ថាប័នរបស់ខ្លួន ស្របតាមនីតិវិធីរបស់ខ្លួនផ្ទាល់។

### *មាត្រា ៣៤ ៖*

ជនជាតិដើមភាគតិចមានសិទ្ធិក្នុងការលើកកំពស់បង្កើត និងរក្សារចនាសម្ព័ន្ធស្ថាប័នរបស់ខ្លួន និងទំនៀមទំលាប់ សាសនា ប្រពៃណី នីតិវិធី វិធីប្រតិបត្តិជាពិសេសរបស់ពួកគេ ហើយក្នុងករណីដែលមានប្រព័ន្ធវិនិច្ឆ័យក្តី ឬការវិនិច្ឆ័យក្តីតាមទំនៀមទំលាប់ ត្រូវស្របតាមបទដ្ឋានសិទ្ធិមនុស្សអន្តរជាតិនានា។

***មាត្រា ៣៥ :***

ជនជាតិដើមភាគតិចមានសិទ្ធិកំណត់ការទទួលខុសត្រូវរបស់បុគ្គលគ្រប់រូប ក្នុងសហគមន៍របស់ពួកគេ។

***មាត្រា ៣៦ :***

១. ជនជាតិដើមភាគតិច ជាពិសេសជនទាំងឡាយដែលត្រូវបានបែងចែកដោយព្រំដែនអន្តរជាតិ មានសិទ្ធិរក្សា និងបង្កើតទំនាក់ទំនង កិច្ចប្រាស្រ័យគ្នា និងការសហការគ្នា រួមទាំងសកម្មភាពនានា ក្នុងគោលបំណងខាងជំនឿសាសនា វប្បធម៌ នយោបាយ សេដ្ឋកិច្ច និងសង្គមកិច្ច ជាមួយនិងសមាជិកផ្ទាល់របស់ពួកគេ ក៏ដូចជា ជាមួយអ្នកដទៃទៀតដែលនៅក្រៅព្រំដែន។

២. រដ្ឋទាំងឡាយ ដោយមានការពិគ្រោះយោបល់ និងការសហការជាមួយជនជាតិដើមភាគតិច ត្រូវចាត់វិធានការប្រកបដោយប្រសិទ្ធភាព ដើម្បីសំរបសំរួលដល់ការប្រើប្រាស់ និងធានាដល់ការអនុវត្តសិទ្ធិទាំងនេះ។

***មាត្រា ៣៧ ៖***

១. ជនជាតិដើមភាគតិច មានសិទ្ធិចំពោះការទទួលស្គាល់ ការគោរពប្រតិបត្តិ និងការអនុវត្តសន្ធិសញ្ញា កិច្ចព្រមព្រៀង និងកិច្ចចាត់ចែងក្នុងន័យស្ថាបនាដទៃទៀត ដែលបានសំរេចឡើងជាមួយរដ្ឋឬជាមួយឧត្តរាធិការីរបស់ខ្លួន ព្រមទាំងមានសិទ្ធិឱ្យរដ្ឋផ្តល់កិត្តិយស និងគោរពសន្ធិសញ្ញា កិច្ចព្រមព្រៀងទាំងនោះ និងកិច្ចចាត់ចែងក្នុងន័យស្ថាបនាផ្សេងទៀត ។

២. គ្មានបញ្ញត្តិណាមួយនៃសេចក្តីប្រកាសនេះ អាចត្រូវបានធ្វើការបកស្រាយដើម្បីកាត់បន្ថយ ឬបំបាត់សិទ្ធិជនជាតិដើមភាគតិច ដែលមានក្នុងសន្ធិសញ្ញា កិច្ចព្រមព្រៀង និងកិច្ចចាត់ចែងក្នុងន័យស្ថាបនាដទៃទៀតឡើយ ។

***មាត្រា ៣៨ ៖***

រដ្ឋទាំងឡាយ ដោយមានការពិគ្រោះយោបល់ និងសហការជាមួយជនជាតិដើមភាគតិច ត្រូវចាត់វិធានការសមស្រប រួមទាំងវិធានការតាមផ្លូវច្បាប់ផង ដើម្បីសំរេចគោលដៅនៃសេចក្តីប្រកាសនេះ ។

## មាត្រា ៣៩ ៖

ជនជាតិដើមភាគតិច មានសិទ្ធិក្នុងការទទួលជំនួយហិរញ្ញវត្ថុ និងជំនួយបច្ចេកទេសពីរដ្ឋ និងតាមរយៈកិច្ចសហការអន្តរជាតិ ដើម្បីទទួលបាននូវសិទ្ធិ ដែលមានចែងក្នុងសេចក្តីប្រកាសនេះ។

## មាត្រា ៤០ ៖

ជនជាតិដើមភាគតិច មានសិទ្ធិទទួលបាននូវសេចក្តីសំរេចដោយឆាប់រហ័ស តាមរយៈនីតិវិធីត្រឹមត្រូវ និងយុត្តិធម៌ចំពោះដំណោះស្រាយលើជំលោះ និងវិវាទជាមួយរដ្ឋ ឬភាគីផ្សេងទៀត ក៏ដូចជាវិធីដោះស្រាយប្រកបដោយប្រសិទ្ធភាព ចំពោះរាល់ការរំលោភសិទ្ធិបុគ្គល និងសិទ្ធិសមូហភាពរបស់ពួកគេ។ សេចក្តីសំរេចនេះ ត្រូវពិចារណាយ៉ាងត្រឹមត្រូវអំពីប្រពៃណី ទំនៀមទំលាប់ វិធាន និងប្រព័ន្ធច្បាប់របស់ជនជាតិដើមភាគតិចពាក់ព័ន្ធ និងសិទ្ធិមនុស្សអន្តរជាតិនានា។

## មាត្រា ៤១ ៖

អង្គការ និងទីភ្នាក់ងារឯកទេសនៃប្រព័ន្ធអង្គការសហប្រជាជាតិ និងអង្គការអន្តររដ្ឋាភិបាលនានា ត្រូវរួមចំណែកជំរុញឱ្យមានការធ្វើឱ្យសំរេចបានពេញលេញនូវបទបញ្ញត្តិ នៃសេចក្តីប្រកាសនេះ តាមរយៈការគៀងគរ នៃកិច្ចសហប្រតិបត្តិការខាងផ្នែកហិរញ្ញវត្ថុ និងជំនួយបច្ចេកទេស។ វិធី និងមធ្យោយផ្សេងៗដែលធានាឱ្យមានការចូលរួមពីសំណាក់ជនជាតិដើមភាគតិច ទាក់ទងនឹងបញ្ហាទាំងឡាយ ដែលប៉ះពាល់ដល់ពួកគេ។

## មាត្រា ៤២ ៖

អង្គការសហប្រជាជាតិ ស្ថាប័ននានារបស់ខ្លួន រួមមានវេទិកាអចិន្ត្រៃយ៍ស្តីពីបញ្ហាជនជាតិដើមភាគតិច និងទីភ្នាក់ងារឯកទេសនានា រួមទាំងនៅថ្នាក់ជាតិ ហើយរដ្ឋត្រូវលើកកំពស់ការគោរព និងការអនុវត្តទាំងស្រុងនូវបទបញ្ញត្តិ នៃសេចក្តីប្រកាសនេះ និងតាមដានលើប្រសិទ្ធភាពនៃសេចក្តីប្រកាសនេះ។

### មាត្រា ៤៣ ៖

សិទ្ធិទាំងឡាយដែលបានទទួលស្គាល់ក្នុងសេចក្តីប្រកាសនេះ បង្កើតបានជាបទដ្ឋានអប្បរមាសំរាប់ការរស់នៅ សេចក្តីថ្លៃថ្នូរ និងសុខុមាលភាពរបស់ជនជាតិដើមភាគតិច លើពិភពលោក ។

### មាត្រា ៤៤ ៖

សិទ្ធិ និងសេរីភាពទាំងអស់ ដែលបានទទួលស្គាល់ ក្នុងសេចក្តីប្រកាសនេះ ត្រូវបានធានាការពារដោយស្មើគ្នាចំពោះជនជាតិដើមភាគតិច ទាំងបុរស និងស្ត្រី ។

### មាត្រា ៤៥ ៖

គ្មានបទបញ្ញត្តិណាមួយក្នុងសេចក្តីប្រកាសនេះ ត្រូវបានធ្វើការបកស្រាយ ដើម្បីកាត់បន្ថយ ឬបំបាត់សិទ្ធិទាំងឡាយដែលជនជាតិដើមភាគតិចមាននាបច្ចុប្បន្ន ឬអាចមាននៅថ្ងៃអនាគតឡើយ ។

***មាត្រា ៤៦ ៖***

១. គ្មានបទបញ្ញត្តិណាមួយក្នុងសេចក្ដីប្រកាសនេះត្រូវបាន ធ្វើការបកស្រាយដោយមិនច្បាស់លាស់ ដោយរដ្ឋណាមួយ ប្រជាពលរដ្ឋ ឬក្រុមណាមួយ ឬបុគ្គលណាម្នាក់ នូវសិទ្ធិណាមួយ ដើម្បីចូលរួមក្នុងសកម្មភាពនានា ឬដើម្បីប្រព្រឹត្តអំពើណាមួយ ផ្ទុយនឹងធម្មនុញ្ញសហប្រជាជាតិ ឬដើម្បីធ្វើការបកស្រាយថាជាការផ្ដល់សិទ្ធិអំណាច ឬលើកទឹកចិត្តឱ្យមានទង្វើណាមួយ ដែលនាំឱ្យមានការបែងចែក ឬធ្វើឱ្យអន់ថយទាំងស្រុង ឬមួយផ្នែកនៃបូរណភាពដែនដី ឬឯកភាពនយោបាយនៃរដ្ឋអធិបតេយ្យ និងឯករាជ្យឡើយ ។

២. ក្នុងការប្រើប្រាស់សិទ្ធិទាំងឡាយ ដែលមានចែងក្នុងសេចក្ដីប្រកាសនេះ សិទ្ធិមនុស្ស និងសេរីភាពជាមូលដ្ឋានសំរាប់មនុស្សទាំងអស់គ្នាត្រូវបានគោរព។ ការប្រើប្រាស់សិទ្ធិទាំងឡាយ ដែលមានចែងក្នុងសេចក្ដីប្រកាសនេះ អាចត្រូវដាក់ឱ្យស្ថិតក្រោមលក្ខខណ្ឌនៃការកំហិតព្រំដែន ដោយមាន

ការកំណត់ដោយច្បាប់តែប៉ុណ្ណោះ ហើយត្រូវស្របតាមកាតព្វកិច្ចសិទ្ធិមនុស្សអន្តរជាតិ។ ការកំណត់លក្ខខណ្ឌបែបនេះ ត្រូវធ្វើឡើងដោយគ្មានការរើសអើង ហើយដែលចាំបាច់បំផុតសំរាប់តែគោលបំណង ដើម្បីធានាការទទួលស្គាល់ និងការគោរពយ៉ាងត្រឹមត្រូវ ចំពោះសិទ្ធិ និងសេរីភាពអ្នកដទៃ និងឆ្លើយតបនឹងលក្ខខណ្ឌយុត្តិធម៌ និងបន្ទាន់បំផុតនៃសង្គមប្រជាធិបតេយ្យ។

៣. បទបញ្ញត្តិដែលមានចែងក្នុងសេចក្តីប្រកាសនេះត្រូវធ្វើការបកស្រាយស្របតាមគោលការណ៍យុត្តិធម៌ ប្រជាធិបតេយ្យ គោរពសិទ្ធិមនុស្ស សមភាព ភាពគ្មានការរើសអើង អភិបាលកិច្ចល្អ និងសុច្ចរិត។